00223747

A190/II/8

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ១២) |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៨ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / SEP / 2008
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Fry

## សំណើឆ្លើយតបរបស់លោក អៀង សារី ចំពោះសារណាតបរបស់សហព្រះរាជអាជ្ញានៅនឹង បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ

**អ្នកដាក់ឯកសារ៖**

សហមេធាវីរបស់លោក អៀង សារី

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / SEP / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Fry

**អ្នកទទួលឯកសារ៖**

អង្គបុរេជំនុំជម្រះ

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

សហព្រះរាជអាជ្ញា

លោកស្រី ជា លាង

លោក Robert PETIT

តាមរយៈសហមេធាវីរបស់គាត់ (ហៅថា "មេធាវីការពារ") តទៅនេះ លោក **អៀង សារី** អនុលោមតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ[1] សូមដាក់សំណើឆ្លើយតបនេះចំពោះសារណាតបរបស់ការិយាល័យសហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ (ហៅថា "សារណាតបរបស់ ក.ស.ព") ដែលដាក់នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ហើយជូនដំណឹងទៅភាគីទាំងអស់នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៨ ។

## I. **ទន្សឹករណ៍សង្ខេប**

1 ការប៉ុនប៉ងដោយ ក.ស.ព ដើម្បីដាក់កម្រិតវិសាលភាពនៃអ្វី ដែលបង្កើតបានជាការបដិសេធនូវសំណើសុំបើកកិច្ចស៊ើបសួរ ក្រោមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង គឺគ្មានមូលដ្ឋានច្បាប់ ឬមិនសមហេតុផល ។

2. អំណះអំណាងរបស់ ក.ស.ព ទាក់ទងនឹងបញ្ហាដែលមានលក្ខណៈសំខាន់ថាតើឯកសារទាំងអស់នៅក្នុងសំណុំរឿងដែលគួរត្រូវបកប្រែជាភាសាអង់គ្លេស និងភាសាខ្មែរ គឺមិនមានគុណសម្បត្តិ ឬមិនពាក់ព័ន្ធ ។ ជាជាងការពន្យល់ថា ហេតុអ្វីបានជាភស្តុតាងដែលមានសារៈសំខាន់ដល់មេធាវីការពាររបស់លោក **អៀង សារី** មិនគួរត្រូវបានបកប្រែនោះ ក.ស.ព បែរជាផ្តោតការយកចិត្តទុកដាក់លើការវាយឈ្មោះឯកសារដែលបានបកប្រែរួចទៅវិញ ។ ជាងនេះទៅទៀត យុត្តិសាស្ត្រចេញពីតុលាការ ICC, ICTR និងតុលាការ ICTY គឺមិនពាក់ព័ន្ធ ហើយក៏មិនសម្រួលនៅក្នុងបរិបទនៃប្រព័ន្ធខុសគ្នាយ៉ាងខ្លាំង ដែលអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញ (អ.វ.ត.ក) ដែរ ។

3. ប្រព័ន្ធ ឬ គោលនយោបាយរបស់ ក.ស.ច.ស សម្រាប់ការបកប្រែឯកសារ ដូចដែលបានកំណត់នៅក្នុងដីកាសម្រេចស្តីពីការបកប្រែ គឺមិនអាចដំណើរការបាន និងគ្មានប្រសិទ្ធិភាព ដោយវាគ្រាន់តែធ្វើអោយកើនឡើងនូវការរំលោភបំពានលើគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តីគ្នា ជាជាងការកាត់បន្ថយការរំលោភបំពាននេះ។ បន្ថែមពីលើនេះ កាតព្វកិច្ចសន្មតនៃកិច្ចសហការគ្នារវាងសមាជិកនៃក្រុមមេធាវីការពារក្តី កំណត់ដោយ ក.ស.ច.ស និងគាំទ្រដោយ ក.ស.ព <u>ប្រហែលមិនអាច</u>ប្រើប្រាស់ ដើម្បីធ្វើយុត្តិកម្មមកលើការរំលោភបំពានដែលចេះតែបន្តមកលើសិទ្ធិរបស់លោក

---

[1]ករណី លោក អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ១២) សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ។ នៅក្នុងសេចក្តីសំរេចនេះ អង្គបុរេជំនុំជម្រះផ្តល់ពេលចំនួន ៧ថ្ងៃ ដល់លោក អៀង សារី ដើម្បីដាក់សំណើឆ្លើយតប ។

**អៀង សារី** គឺសិទ្ធិចូលរួមក្នុងកិច្ចការពារក្តីរបស់ខ្លួន និង សិទ្ធិទទួលបានកិច្ចការពារក្តីប្រកបដោយប្រសិទ្ធិភាព ។

## II. ច្បាប់

4. ច្បាប់នៅជាធរមានអនុវត្តសម្រាប់សម្រេចលើបណ្តឹងឧទ្ធរណ៍នេះ គឺបានកំណត់នៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែរបស់លោក **អៀង សារី** [2] ។

## III. ឧឡឹករណ៍

### ក. បណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែអាចទទួលយកបាន

5. ការលើកឡើងរបស់ ក.ស.ព ថា បណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែនេះមិនអាចទទួលយកបានទេ ដោយសារតែ "វិធាន៧៤(៣) រៀបរាប់គ្មានសល់នូវប្រភេទដីកាដែលជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ"[3] ហើយថា វិធាននេះ "មិនបានគិតទុកជាមុនអំពីបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាសម្រេចណាមួយដែលបដិសេធសំណើសុំបកប្រែឯកសារ ទៅជាភាសារបស់ជនត្រូវចោទ ឬ មេធាវីការពាររបស់គាត់"[4] គឺមិនទាក់ទងគ្នា ។ បណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែនេះត្រូវបានធ្វើឡើងដោយឈរលើមូលដ្ឋានដែលថា ដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ (ហៅថា "ដីកាសម្រេចស្តីពីការបកប្រែ")[5] គឺជាការបដិសេធលើពាក្យសុំអោយមានកិច្ចស៊ើបសួរ ហេតុដូច្នេះ ដីកានេះអាចប្តឹងឧទ្ធរណ៍បានស្របតាមវិធាន ៧៤(៣)(ខ)[6] ។

---

[2] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចលើសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ១, ៣, ៩ ដល់ ១០, ២០ ដល់ ២៣ ។

[3] សារណាតបរបស់ ក.ស.ព កថាខណ្ឌ ២៦ ។

[4] ដូចខាងលើ ។

[5] អ.ប.ជ នៅក្នុងសេចក្តីសំរេចថ្មីៗលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងលោក ដេវិឌ ប៊ីយ បានយល់ឃើញថា វិធាន ៧៤(៣) មិនអនុញ្ញាតអោយប្តឹងឧទ្ធរណ៍ប្រឆាំងចំពោះ*សេចក្តីសំរេច* របស់ ក.ស.ច.ស ហេតុដូច្នេះហើយ អ.ប.ជ "មិនមានយុត្តាធិការទៅលើបណ្តឹងឧទ្ធរណ៍នេះទេ" ។ ករណី លោក អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០៨) សាលដីកាស្តីពីបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ចំពោះលិខិតដែលពាក់ព័ន្ធនឹងសំណើសុំព័ត៌មានអំពីមន្ត្រីច្បាប់ លោក ដេវីឌ ប៊ីយល់ ចុះថ្ងៃទី ២៨ សីហា ២០០៨ កថាខណ្ឌ ១៧ ។ ប៉ុន្តែ យោងតាមវិធាន ៧៤(៣)

00223750



6. ពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរក្រោមវិធាន ៧៤(៣)(ខ) ក.ស.ព បានអះអាងថា "ការស្វះស្វែងអោយមានការបកប្រែឯកសារ គឺមិនឈានទៅដល់ការស្វះស្វែងអោយមានកិច្ចស៊ើបសួរឡើយ"[7] ហើយថាការបកប្រែគឺគ្រាន់តែជា "បញ្ហារដ្ឋបាលរបស់តុលាការតែប៉ុណ្ណោះ"[8] ។ ក.ស.ព ខកខានមិនបានធ្វើយុត្តិកម្មអំពីទស្សនៈដ៏ចង្អៀតចង្អល់ចំពោះកិច្ចស៊ើបសួរនោះទេ ។

7. មេធាវីការពារបានដាក់សំណើផ្លូវការចំនួនពីរទៅ ក.ស.ច.ស ស្នើអោយបំពេញកិច្ចស៊ើបសួរនៃការរៀបចំការបកប្រែឯកសារទាំងអស់ ដែលអះអាងថាគាំទ្រដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[9] ។ សំណើទាំងពីរនេះ មិនមែនជាសំណើសុំបកប្រែឯកសារ ដែលដាក់ស្នើជាទម្លាប់ដោយភាគីនីមួយៗ ទៅក្រុមអ្នកបកប្រែផ្ទាល់មាត់ និងបកប្រែសំណេរ (ហៅកាត់ថា "ក្រុមអ្នកបកប្រែ")តាមប្រព័ន្ធអេឡិចត្រូនិច (online) របស់ អ.វ.ត.ក ។ ខណៈដែលសំណើសុំបកប្រែឯកសារទៅ ក្រុមអ្នកបកប្រែITP បើសិនត្រូវបដិសេធដោយក្រុមនេះ គឺពិតជាមិនអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបានទេ (ប៉ុន្តែវាអាចអោយប្តឹងតាមបែបបទរដ្ឋបាលទៅប្រធានរដ្ឋបាលបាន)។ សំណើដែលមេធាវីការពារដាក់ជូនទៅ ក.ស.ច.ស គឺពិតជាសំណើខុសគ្នា ដែលប៉ះពាល់ដល់សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌ទាំងមូលរបស់លោក **អៀង សារី**[10] ។

8. នៅក្នុងការវាយឈ្មោះកិច្ចស៊ើបសួរ ដែលត្រូវធ្វើដោយសហចៅក្រមស៊ើបអង្កេតស្របតាមវិធាន ៥៥(៥) ក.ស.ព សន្និដ្ឋានថា សេចក្តីសម្រេចលើសំណើសុំការបកប្រែ "មិនចូលទៅក្នុងកិច្ចស៊ើប

---

អ.ប.ជ អាចពិនិត្យឡើងវិញនូវដីកាសម្រេចខ្លះៗ ដែលចេញដោយ ក.ស.ច.ស ។ នៅក្នុងករណីកំពុងពិនិត្យមើលនេះ ក.ស.ច.ស បានចេញដីកាសម្រេច ដូច្នេះ អ.ប.ជ មិនបដិសេធថាខ្លួនមិនមានយុត្តាធិការលើបណ្តឹងដោយឈរលើមូលដ្ឋាននេះឡើយ។

[6] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ១ ដល់ ៦ ។

[7] សារណាតបរបស់ ក.ស.ព កថាខណ្ឌ ៣០ ។

[8] សារណាតបរបស់ ក.ស.ព កថាខណ្ឌ ៣២ ។

[9] សូមមើលករណីលោក អៀង សារី សំណុំរឿងលេខ ០០២/១៨-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើសុំពន្លឿនការបកប្រែឯកសារទាំងអស់ ដែលគាំទ្រដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ (ហៅថា "សំណើសុំពន្លឿនការបកប្រែ")។ ករណីលោក អៀង សារី សំណុំរឿងលេខ ០០២/១៨-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស លិខិតមានចំណងជើងថា "ពុំមានការឆ្លើយតបទៅនឹងសំណើសុំពន្លឿនការបកប្រែឯកសារទាំងអស់ដែលគាំទ្រដល់ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ទៅជាភាសាខ្មែរ និង ភាសាអង់គ្លេស ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ ។

[10] *សូមមើល* មាត្រា ២៤ នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ជាមួយវិសោធនកម្មដែលប្រកាសអោយប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ដូចដែលបានពិភាក្សានៅក្នុងកថាខណ្ឌ២២ ដល់ ២៦ នៃបណ្តឹងឧទ្ធរណ៍ ។

សួរទាំងអស់នេះទេ ហេតុដូច្នេះ គេមិនអាចពិចារណាថាជាកិច្ចស៊ើបសួរបានឡើយ”[11] ។ ប៉ុន្តែ ក.ស.ព ទទួលស្គាល់ថា នេះគ្រាន់ជា “បញ្ជីចង្អុលបង្ហាញមួយប៉ុណ្ណោះ”[12] ។ អាស្រ័យហេតុនេះ អវត្តមាននៅក្នុងវិធាន ៥៥(៥) នៃការសម្រេចលើសំណើសុំការបកប្រែសំណុំរឿងទាំងមូល មិនមែនកំណត់ថាតើ សកម្មភាពបែបនេះបង្កើតបានជាកិច្ចស៊ើបសួរដែរឬទេ ។ បញ្ជីចង្អុលបង្ហាញ គ្រាន់តែបង្ហាញពីប្រភេទនៃសកម្មភាពទាំងឡាយណាដែលត្រូវបានចាត់ទុកថា ចូលក្នុងលក្ខណៈ វិនិច្ឆ័យមួយ ហើយវាមិនមែនជាបញ្ជីរៀបរាប់គ្រប់សព្វនោះដែរ ដែលតាមលក្ខណៈធម្មជាតិ បញ្ជី រៀបរាប់សព្វគ្រប់នេះត្រូវតែរាយឈ្មោះសកម្មភាពទាំងអស់ដែលចូលទៅក្នុងលក្ខណៈវិនិច្ឆ័យ ។ ខ្លឹមសារនៃសកម្មភាពដែលស្នើសុំឱ្យ ក.ស.ច.ស បំពេញ ត្រូវតែបានគេពិចារណាដើម្បីកំណត់ថា តើវាបង្កើតបានជាកិច្ចស៊ើបសួរ និងចូលទៅក្នុងវិធាន ៧៤(៣)(ខ) ដែរទេ ជាជាងគ្រាន់តែពិនិត្យ ឈ្មោះរបស់សំណើនោះ ។ ចំពោះមូលហេតុដូចដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការ បកប្រែ[13] ដីកាសម្រេចស្តីពីការបកប្រែ បង្កើតបានជាការបដិសេធពាក្យសុំអោយមានកិច្ចស៊ើបសួរ យ៉ាងច្បាស់ក្រឡែត ហេតុដូច្នេះ ដីកានេះអាចប្តឹងឧទ្ធរណ៍បាន ក្រោមវិធាន ៧៤(៣)(ខ) ។

**ខ. ប្រព័ន្ធស៊ើបសួររបស់ អ.វ.ត.ក តម្រូវថា ឯកសារទាំងអស់នៅក្នុងសំណុំរឿងត្រូវតែបកប្រែទៅជា ភាសារបស់ជនត្រូវចោទ**

9. ក.ស.ព លើកឡើងនូវមូលហេតុចំនួន៨ ថាហេតុអ្វីបានជាលោក **អៀង សារី** មិនមានសិទ្ធិអោយ មានការបកប្រែឯកសារទាំងអស់នៅក្នុងសំណុំរឿងទៅជាភាសាខ្មែរ ។ ជារឿយៗ បរិមាណគ្រាន់ តែជារនាំងបិទបាំងនូវភាពខ្វះគុណភាព និង ពុំសូវមានភាពទាក់ទងគ្នារបស់ទឡ្ហីករណ៍ប៉ុណ្ណោះ ។

10. អំណោះអំណាងទីមួយដែលលើកឡើងដោយ ក.ស.ព គឺថាលោក **អៀង សារី** បន្ថែមពីលើ ភាសាខ្មែរ មានភាពស្ទាត់ជំនាញប្រហាក់ប្រហែលគ្នាខាងភាសាបារាំង”[14] ។ នេះបង្កប់ន័យថា លោក **អៀង សារី** អាចត្រួតពិនិត្យភស្តុតាងជាភាសាបារាំងបាន ហើយមិនតម្រូវអោយបកប្រែ ភស្តុតាងទាំងនោះទៅជាភាសាខ្មែរឡើយ ។ ជានីតិវិធី ក.ស.ព ត្រូវបានហាមឃាត់មិនអោយលើក

---

[11] សារណាតបរបស់ ក.ស.ព កថាខណ្ឌ ៣១ ។

[12] សារណាតបរបស់ ក.ស.ព កថាខណ្ឌ ៣០ ។

[13] បណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែ កថាខណ្ឌ ៣ ។

[14] សារណាតបរបស់ ក.ស.ព កថាខណ្ឌ ៣៤ ។

ឡើងអំណះអំណាងនេះទេ ។ នៅក្នុងដីកាសម្រេចស្តីពីការបកប្រែ ក.ស.ច.ស បានលើកឡើងថា "មិនមានជនត្រូវចោទណាម្នាក់ ទទួលស្គាល់ជាផ្លូវការថាខ្លួនមានសមត្ថភាពចេះភាសាផ្លូវការណាមួយផ្សេងទៀតរបស់តុលាការ"[15] ។ ប្រសិនបើ ក.ស.ព មានបំណងជំទាស់ទៅនឹងមូលហេតុដែលថាលោក **អៀង សារី** បានជ្រើសរើសប្រើភាសាខ្មែរ (ជាភាសាកំណើតរបស់គាត់) ផ្ទុយពីភាសាបារាំង ដែលជាភាសាធ្វើការរបស់គាត់នៅអង្គជំនុំជម្រះវិសាមញ្ញ ពួកគេគួរតែបានប្រើប្រាស់សមត្ថភាពគ្មានដែនកំណត់របស់ពួកគេ ដើម្បីប្តឹងជំទាស់សេចក្តីសម្រេចទាំងឡាយដែលចេញដោយ ក.ស.ច.ស ក្រោមវិធាន ៧៤(២) ដើម្បីជំទាស់ថាលោក អៀង សារី អាចយល់ដឹងភស្តុតាងជាភាសាបារាំង ហេតុដូច្នេះ គាត់ត្រូវបានហាមឃាត់ក្នុងការទទួលភស្តុតាងជាភាសាខ្មែរដែលប្រើប្រាស់ដោយ ក.ស.ព និង ក.ស.ច.ស ។ ការខកខានប្រើប្រាស់សិទ្ធិនេះ ក.ស.ព ត្រូវបានហាមលើកអំណះអំណាងនេះ នៅពេលនេះ ។

11. សំខាន់ជាងនេះទៅទៀត នៅពេលដឹងយ៉ាងច្បាស់ថា លោក **អៀង សារី** អាចនិយាយ និងយល់ភាសាបារាំងក្នុងកម្រិតជាក់លាក់មួយ ក.ស.ព មិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ថា លោក **អៀង សារី** អាចប្រើប្រាស់សិទ្ធិរបស់គាត់បានយ៉ាងពេញលេញ ដើម្បីចូលរួមក្នុងកិច្ចការពារក្តីរបស់គាត់តាមរយៈការពិនិត្យផ្ទៀងផ្ទាត់ និង វិភាគគ្រប់ជ្រុងជ្រោយលើភស្តុតាងជាភាសាបារាំងនេះ ។ ដូចដែលតុលាការ ICC បានសម្រេចថា "ប្រសិនបើមានមន្ទិលសង្ស័យណាមួយទៅលើថាតើបុគ្គលម្នាក់យល់ និង និយាយយ៉ាងពេញលេញនូវភាសារបស់តុលាការ នោះភាសាដែលស្នើឡើងដោយសាម៉ីជននេះត្រូវតែបានសម្រួល"[16]។ ហេតុដូច្នេះ ប្រសិនបើលោក **អៀង សារី** ចង់បាននូវសម្ភារៈឯកសារដែលស្នើសុំ អោយផ្តល់មកខ្លួនជាភាសាខ្មែរ សំណើបែបនេះត្រូវតែបានសម្រួលដោយពិចារណាជាពិសេសទៅលើអាយុ និង ស្ថានភាពសុខភាពបច្ចុប្បន្នរបស់គាត់ ។

12. អំណះអំណាងទី២ ទី៣ និងទី៤[17]ដែលលើកឡើងដោយ ក.ស.ព មិនទាក់ទងនឹងបញ្ហាថាតើលោក **អៀង សារី** ត្រូវតែទទួលបាននូវឯកសារទាំងអស់ដែលអះអាងគាំទ្រដល់ដីកាបញ្ជូនរឿងទៅស៊ើបសួរនោះទេ ។ អំណះអំណាងទាំងនេះគ្រាន់តែរាយឈ្មោះឯកសារដែលបានបកប្រែ ឬ នឹងត្រូវ

---

15 ដីកាបកប្រែ កថាខណ្ឌ ៣១ ។

16 ករណី ព្រះរាជអាជ្ញាតទល់ជាមួយ Katanga, ICC-01/04-01/07 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Germain Katanga ប្រឆាំងលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ដែលមានចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារ ទាក់ទងទៅនឹងភាសា ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ កថាខណ្ឌ៣ ។

17 សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌទី ៣៥ ដល់ទី៣៧ ។

បកប្រែ ជាភាសាខ្មែរ ដូចជា លេខយោង និង លិបិក្រម ដែលដាក់អមជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ និងសម្ភារៈឯកសារជាភស្តុងតាងដែលប្រមូលដោយ ក.ស.ច.ស និងសារណានានាតែប៉ុណ្ណោះ ។ តាមរយៈការបង្ហាញឲ្យឃើញនូវឯកសារភស្តុតាងភាគច្រើន ដែលបង្កើតជាផ្នែកមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ជាភាសាខ្មែរ និង/ឬភាសាបារាំង ក.ស.ព ទទួលស្គាល់អំពីសារៈសំខាន់នៃការផ្តល់នូវសម្ភារៈឯកសារទាំងអស់នេះទៅលោក **អៀង សារី** ។ ជាការកត់សំគាល់ ក.ស.ព ខកខានមិនបានធ្វើយុត្តិកម្មថាហេតុអ្វីបានជាភស្តុតាងដែលបានស្នើសុំទាំងអស់នេះមិនគួរត្រូវបានគេបកប្រែ ។

13. អំណោះអំណាងទី៥ ដែលលើកឡើងដោយ ក.ស.ព គឺ កាតព្វកិច្ចសន្មតនៃកិច្ចសហការគ្នារបស់ក្រុមមេធាវីការពារ[18] ។ ការពិតដែលថាសមាជិកខ្លះនៃក្រុមមេធាវីការពារមាន“បទពិសោធន៍ការងារយ៉ាងទូលំទូលាយនៅកម្ពុជា” ឬក៏ជា “សមាជិកគណៈមេធាវីសហរដ្ឋអាមេរិក” គឺមិនពាក់ព័ន្ធគ្នាទេ ។

14. សមត្ថភាពខាងអក្សរសាស្ត្រខ្មែររបស់សមាជិកខ្លះនៃក្រុមមេធាវីការពារលោក **អៀង សារី** <u>មិនត្រូវ</u> យកមកធ្វើជាសំអាងដើម្បីធ្វើយុត្តិកម្មនៃការរំលោភបំពានសិទ្ធិរបស់លោក **អៀង សារី** ក្នុងការចូលរួមយ៉ាងពេញលេញជាជំនួយដល់កិច្ចការពារក្តីរបស់គាត់ឡើយ ។ សិទ្ធិនេះគឺជាសិទ្ធិដាច់ដោយឡែក និងបន្ថែមលើសិទ្ធិទទួលបានកិច្ចការពារក្តីប្រកបដោយប្រសិទ្ធិភាពរបស់គាត់[19] ។

15. អំណោះអំណាងទី៦ ដែលលើកឡើងដោយ ក.ស.ព គឺថាក្រុមមេធាវីការពារដាក់ឯកសារជាភាសាអង់គ្លេសតែមួយគត់ តាំងពីមុនពេលធ្វើវិសោធនកម្មលើសេចក្តីណែនាំអនុវត្តនៅខែមេសា ឆ្នាំ ២០០៨[20] ។ ចំនុច នេះក៏មិនជាប់ពាក់ព័ន្ធជាមួយបញ្ហាបច្ចុប្បន្ននេះដែរ ។ ឯកសារ នានាដែលដាក់ដោយក្រុមមេធាវីការពារមិនត្រូវការពិនិត្យផ្ទៀងផ្ទាត់ដោយលោក **អៀង សារី** ក្នុងកម្រិតយ៉ាងល្អិត

---

18 សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៣៨ ។

19 សិទ្ធិនីមួយៗនៃសិទ្ធិទាំងនេះត្រូវវិភាគយ៉ាងល្អិតល្អន់ក្នុងការដាក់ឯកសារពីមុនរបស់មេធាវីការពារ ។ *ជាឧទាហរណ៍ សូមមើល* រឿងក្តីលោក អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០៣) សំណើសុំបន្ទាន់សុំអោយពន្យារពេលអោយបានសមស្របដើម្បីដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ និង ការឆ្លើយតបទៅនឹងសារណារបស់ការិយាល័យសហព្រះរាជអាជ្ញា យោងតាមការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៨ កុម្ភៈ ២០០៨ ។ រឿងក្តីលោក អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើសុំឲ្យអ្នកជំនាញផ្នែកចិត្តសាស្ត្រពិនិត្យសុខភាពលោក អៀង សារី ដើម្បីសម្រេចពីសម្បទាក្នុងការចូលរួមក្នុងសវនាការ ចុះថ្ងៃទី ១៤ មីនា ២០០៨ ។

20 សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៣៩ ។

ល្អន់ដូចគ្នានឹងភស្តុតាងដែលអាចត្រូវបានប្រើប្រាស់សម្រាប់ផ្តន្ទាទោសគាត់ ឬ អោយគាត់រួចទោសឡើយ ។ ការចូលរួមចំណែករបស់លោក **អៀង សារី** ក្នុងការដាក់ឯកសាររបស់មេធាវីការពារ ខណៈពេលដែលមានសារៈសំខាន់ជាសារវ័ន្ត អាចធ្វើឡើងដោយផ្ទាល់មាត់ ដូចដែលធ្លាប់បានធ្វើកន្លងរួចមកហើយ ។

16. អំណះអំណាងទី ៧ ដែលលើកឡើងដោយ ក.ស.ព គឺជាការយោងសំដៅទៅយុត្តិសាស្ត្ររបស់តុលាការ ICTY តុលាការ ICTR និង តុលាការ ICC ។ ក.ស.ព អះអាងថា របបដែលដាក់អោយអនុវត្តនៅក្នុង ដីកាសម្រេចស្តីពីការបកប្រែ ឆ្លុះបញ្ចាំងពី "របបសេរីបំផុតនៃការលាតត្រដាងនូវភស្តុតាងដែលអនុម័តយកដោយតុលាការ ICTY និងតុលាការ ICTR"[21]។ នេះគឺជារឿងមិនពិតយ៉ាងជាក់ស្តែង។ ដូចដែលមេធាវីការពារបានគូសចំណាំនៅក្នុង បណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែយ៉ាងហោចណាស់មានអង្គជំនុំជម្រះមួយនៃតុលាការ ICTY បានតម្រូវថា ភស្តុតាងដោះបន្ទុកត្រូវធ្វើការបកប្រែជាភាសារបស់ជនជាប់ចោទ[22]។ របបដែលបង្កើតតាមរយៈ ដីកាសម្រេចស្តីពីការបកប្រែ មិនសូវបំរើផលប្រយោជន៍ឲ្យលោក **អៀង សារី** ទេ បើប្រៀបធៀបជាមួយប្រព័ន្ធនោះ។

17. អំណះអំណាងទី៨ ដែលលើកឡើងដោយ ក.ស.ព គឺថាមេធាវីការពារអាចស្នើសុំឲ្យផ្នែកគ្រប់គ្រងតុលាការបកប្រែឯកសារបន្ថែមទៀត[23] ។ ប៉ុន្តែ ដូចគ្នានឹងអ្វីដែលបង្កើតបានជាការរំលោភបំពានសមភាពនៃមធ្យោបាយតទល់ក្តីគ្នា ដែលនឹងថ្លែងប្រាស្រ័យនៅខាងក្រោម សិទ្ធិនេះគ្រាន់តែទ្រឹស្តីតែប៉ុណ្ណោះ ។ មានតែ ឯកសារដែលត្រូវការដោយអ្នកចូលរួមច្រើននាក់ទេ ទើបត្រូវបានបកប្រែ ធ្វើដូចនេះគឺជាការដាក់សិទ្ធិរបស់លោក **អៀង សារី** ឲ្យនៅក្រោមចំណុះសិទ្ធិរបស់ជនត្រូវចោទដទៃទៀត ភាគីរដ្ឋប្បវេណី និង ក.ស.ព ខ្លួនឯង ។ ការដាក់សិទ្ធិនៅក្រោមចំណុះបែបនេះ បានដកហូតនូវអត្ថន័យជាក់ស្តែងនៃសិទ្ធិនេះ ។

18. សារណាឆ្លើយតបរបស់ ក.ស.ព ខកខានតែមួយគត់ក្នុងការដោះស្រាយចំនុចសំខាន់នៃអំណះអំណាងរបស់មេធាវីការទាក់ទងនឹងអនុវត្តន៍យុត្តិសាស្ត្ររបស់តុលាការ ICC, ICTR និងតុលាការ ICTY ជាពិសេសនៅតុលាការទាំងនេះ "ដំណាក់កាលស៊ើបអង្កេត គឺខុសប្លែកគ្នាយ៉ាងខ្លាំងពី

---

21 សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៤០ ។

22 បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារ កថាខណ្ឌ ១៨ លើកមកសំអាងករណី*ព្រះរាជអាជ្ញាតទល់ជាមួយ Ljubici*, IT-00-41 សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារស្នើសុំការបកប្រែឯកសារទាំងអស់ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០២ ទំព័រ៣ ។

23 សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៤១ ។

ដំណាក់កាលស៊ើបអង្កេតនៅ អ.វ.ត.ក"[24] ។ ក.ស.ព អះអាងថា នៅពេលដែល "អាចនឹងមានការខុសគ្នាជាលក្ខណៈជាប្រព័ន្ធនោះ [...] ការប៉ះប៉ូវដែលត្រូវបានកាត់តម្រឹមដោយវិធាននានា និងត្រូវបានអះអាងទទួលយកនៅក្នុងសេចក្ដីសម្រេចទាក់ទងនឹងការបកប្រែ បានធ្វើឲ្យភាពខុសគ្នាទាំងនោះបើសិនជាមាន មិនមានសារៈសំខាន់"[25] ។ មានការពន្យល់ហេតុផលតែមួយគត់ដែលទំនងជាផ្ដល់ចំពោះហេតុអ្វីការខុសគ្នាទាំងនេះបែរជាមិនមានសារៈសំខាន់ទៅវិញ នោះគឺថា "សិទ្ធិពិនិត្យឯកសាររបស់គាត់ អាចត្រូវបានសម្រួលតាមរយៈកិច្ចសហការនៅក្នុងក្រុមអ្នកច្បាប់របស់គាត់ និងដោយមានជំនួយពីអង្គភាពគាំពារការការពារក្ដី"[26] ។ ចំនុចនេះមិនធ្វើអោយភាពខុសគ្នាខាងលើនេះ "មិនមានសារៈសំខាន់" នោះទេ ប៉ុន្តែ វាបង្កបង្កើតទៅជាការរំលោភបំពាន សមភាពនៃមធ្យោបាយតទល់ក្ដីគ្នា ដោយដាក់បន្ទុកមកលើមេធាវីការពារអោយរៀបចំការបកប្រែនូវឯកសារដែលដាក់ដោយ ក.ស.ព ។

19. ភាពខុសគ្នារវាងប្រព័ន្ធរបស់ អ.វ.ត.ក និង ប្រព័ន្ធរបស់តុលាការអន្តរជាតិដទៃទៀត គឺមានសារៈសំខាន់ ហើយតម្រូវអោយរបបនៃការបកប្រែត្រូវបានកាត់តម្រឹមយ៉ាងជាក់លាក់ចំពោះតុលាការកម្ពុជានេះផងដែរ ។ ឧទាហរណ៍ ប្រព័ន្ធរបស់តុលាការ ICC ប្រតិបត្តិមធ្យោបាយផ្សេងគួរឲ្យកត់សំគាល់នៅដំណាក់កាលស៊ើបអង្កេត ហេតុដូច្នេះ យុត្តិសាស្ត្រចំពោះបញ្ហានេះមិនគួរអនុវត្តដោយស្វ័យប្រវត្តិនៅអង្គជំនុំជម្រះវិសាមញ្ញនោះទេ ។ ស្រដៀងគ្នាទៅនឹងដីកាដំណោះស្រាយរបស់ អ.វ.ត.ក ដែរ សវនាការដើម្បីសម្រេចលើដីកាចោទប្រកាន់ (indictment) នៅតុលាការ ICC នៅពេលដែលរដ្ឋអាជ្ញាបង្ហាញភស្តុតាងជាបឋមប្រឆាំងនឹងជនត្រូវចោទ ត្រូវតែធ្វើឡើងនៅក្នុង " ពេលវេលាសមស្របមួយ បន្ទាប់ពីជនត្រូវចោទប្រគល់ខ្លួន ឬ ចូលខ្លួនដោយស្ម័គ្រចិត្តមកចំពោះមុខតុលាការ"[27] ។ នៅក្នុងករណីមានសវនាការបែបនេះ ហើយទោះបីជាត្រូវបានលើកពេលជាច្រើនលើកច្រើនសារក៏ដោយ ក៏សវនាការទាំងអស់នេះនៅតែធ្វើឡើងយ៉ាងហោចណាស់រយៈពេលប្រាំបី(៨)ខែ[28] ប្រាំបួន(៩)ខែ[29] និងប្រាំ(៥)ខែ[30]ជាបន្តបន្ទាប់ ក្រោយពីការចូល

---

24 បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៦ ។

25 សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៤២ ។

26 សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៤២ ។

27 មាត្រា ៦១(១) នៃលក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការ ICC ។

28 ករណី *ព្រះរាជអាជ្ញា តទល់ជាមួយ Lubanga*, ICC-01/04/01/06 ។ សវនាការលើការចូលខ្លួនដំបូងរបស់ Thomas Lubanga ប្រព្រឹត្តទៅនៅថ្ងៃទី១៧ មីនា ២០០៦ ។ សវនាការសម្រេចលើដីកាចោទប្រកាន់ធ្វើឡើងនៅថ្ងៃទី៩ វិច្ឆិកា ២០០៦ ។

ខ្លួនដំបូងនៅចំពោះមុខតុលាការ ICC ។ ហេតុដូច្នេះនៅពេលដែលមានពេលវេលាខ្លីនៅចន្លោះពេលនៃការចូលខ្លួនដំបូងរបស់ជនត្រូវចោទ និងការចាប់ផ្តើមសវនាការសម្រេចលើដីកាចោទប្រកាន់ តម្រូវការបកប្រែសម្ភារៈឯកសារដោះបន្ទុកទាំងអស់ ឬឯកសារដទៃទៀតដែលចាំបាច់សម្រាប់ការរៀបចំការការពារខ្លួន នោះសវនាការនឹងត្រូវពន្យារពេលជាពុំខានឡើយ ។ អាស្រ័យហេតុនេះ វាមិនមែនជាការគួរឲ្យភ្ញាក់ផ្អើលទេដែលថាសំណើបែបនេះត្រូវបានបដិសេធចោលនោះ[31] ។ ប៉ុន្តែនៅតុលាការ ICC ការបដិសេធការបកប្រែឯកសារនៅដំណាក់កាលនេះ ត្រូវបានទូទាត់សងមកវិញដោយពេលវេលាដែលមានដើម្បីបកប្រែសម្ភារៈឯកសារ បន្ទាប់ពីសវនាការសម្រេចលើដីកាចោទប្រកាន់ ប៉ុន្តែនៅមុនការចាប់ផ្តើមការជំនុំជម្រះក្តី ។ ពេលវេលាបន្ថែមនេះបន្ទាប់ពីសវនាការសម្រេចលើដីកាចោទប្រកាន់ អនុញ្ញាតឲ្យមានការបកប្រែឯកសារដោះបន្ទុកដែលមិនទាន់ត្រូវបានគេបកប្រែ[32] ។

20. ផ្ទុយទៅវិញ ការកំណត់កាលបរិច្ឆេទឲ្យបានឆាប់រហ័សនៅចន្លោះការចេញដីកាដំណោះស្រាយ (closing order) និងការចាប់ផ្តើមបើកសវនាការនៅ អ.វ.ត.ក មិនបានផ្តល់ពេលវេលាឲ្យមេធាវីការពារធ្វើការបកប្រែ និងពិនិត្យឯកសារពាក់ព័ន្ធឡើងវិញបាននោះទេ។ ដោយសារតែភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងប្រព័ន្ធ អ.វ.ត.ក និងប្រព័ន្ធដែលបានអនុម័តយកនៅ ICC, ICTY និង ICTR

---

[29] ករណី *ព្រះរាជអាជ្ញា តទល់ជាមួយ Katanga & Ngudjolo*, ICC-01/04-01/07 ។ សវនាការលើការចូលខ្លួនដំបូងរបស់ Germain Katanga ប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែតុលា ២០០៧ ។ សវនាការសម្រេចលើដីកាចោទប្រកាន់ធ្វើឡើងនៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០៨ ។

[30] ករណី *ព្រះរាជអាជ្ញា តទល់ជាមួយ Katanga & Ngudjolo*, ICC-01/04-01/07 ។ សវនាការលើការចូលខ្លួនដំបូងរបស់ Mathew Ngudjolo Chui ប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែកុម្ភៈ ២០០៨ ។ សវនាការសម្រេចលើដីកាចោទប្រកាន់ធ្វើឡើងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៨ ។

[31] ករណី *ព្រះរាជអាជ្ញា តទល់ជាមួយ Lubanga*, ICC-01/04/01/06 សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារ ចុះថ្ងៃទី ៣ និងទី៤ ខែកក្កដា ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៦ ។

[32] នៅក្នុងរឿងក្តី *Lubanga* រយៈពេលចន្លោះពីសេចក្តីសំរេចលើដីកាចោទប្រកាន់ និងការចាប់ផ្តើមនៃសវនាការអាចមានទៅដល់ ១៧ខែ បើសិនជានីតិវិធីមិនបង្អង់ដោយសារមូលហេតុអ្វីផ្សេងទៀត ។ *ព្រះរាជអាជ្ញា តទល់ជាមួយ Lubanga*, ICC-01/04/01/06 សេចក្តីសំរេចអំពីការទទួលយកការចោទប្រកាន់ ចុះថ្ងៃទី ២៩ មករា ២០០៧ ។ អង្គជំនុំជម្រះលើកក្រោយមកទៀតអះអាងទទួលយកថា កាលបរិច្ឆេទនៃការជំនុំជម្រះក្តីនឹងចាប់ផ្តើមនៅថ្ងៃទី ២៣ មិថុនា ២០០៨ ។ *ព្រះរាជអាជ្ញា តទល់ជាមួយ Lubanga*, ICC-01/04/01/06ប្រតិចារឹកនៃសវនាការថ្ងៃទី ១៣ មីនា ២០០៨ ទំព័រ ១០។

ការផ្លាស់ប្តូរជាស្វ័យប្រវត្តិតាមយុត្តិសាស្ត្រនៃស្ថាប័នទាំងនោះគួរត្រូវបានជៀសវាង ដោយមិនចាំបាច់មានការពិនិត្យលើហេតុផលនៅពីក្រោយយុត្តិសាស្ត្រនេះទេ។

21. ក.ស.ព ហាក់ដូចជាយល់ច្រឡំពីចរិតលក្ខណៈនៃដំណាក់កាលស៊ើបសួរ។ ចំនុចនេះអាចត្រូវបានមើលឃើញតាមការអះអាងរបស់ខ្លួនក្រោយមកថា ទោះបីជារបបនៃបកប្រែមិនមានយុត្តិធម៌ក៏ដោយ ក៏ចំនុចហាក់ទទួលយកបានដោយសារ របបនេះ "មិនបានចែងអំពីសិទ្ធិទទួលបានការបកប្រែ និង កាតព្វកិច្ចរបស់ភាគីនានានៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីនោះទេ"។[33] ការរំលោភសិទ្ធិរបស់លោក **អៀង សារី** ត្រូវតែបញ្ឈប់ជាបន្ទាន់ ហើយប្រហែលជាមិនអាចត្រូវបានជួសជុលឡើងវិញនាពេលក្រោយ តាមរយៈសេចក្តីសម្រេចមួយដែលមានការអនុគ្រោះច្រើនថែមជាងមុននោះទេ។ ដំណាក់កាលស៊ើបសួរគឺជាមូលដ្ឋានគ្រឹះចំពោះការកាត់ក្តី ជាយថាហេតុ ប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។ ហេតុដូច្នេះ ការមិនបានផ្តល់ឲ្យលោក **អៀង សារី** នូវការបកប្រែឯកសារដែលបានស្នើសុំឲ្យទៅជាភាសាខ្មែរ គឺជាការរំលោភសិទ្ធិរបស់គាត់ចំពោះចូលរួមក្នុងកិច្ចការពារខ្លួនគាត់ដោយផ្ទាល់ ដែលអាចប៉ះពាល់ដល់ដំណើរការជំនុំជម្រះក្តីទាំងមូល។

## គ. ការបកប្រែឯកសារទៅជាភាសារបស់សហមេធាវីបរទេស

22. ក.ស.ព អះអាងថា "គឺជាការកំរនឹងមានលិខិតុបករណ៍អន្តរជាតិ ឬប្រភពច្បាប់សម្រាប់យោងណាមួយដែលធ្វើឲ្យតុលាការនេះត្រូវជាប់កាតព្វកិច្ចអនុវត្តតាម ដើម្បីធានាថារាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿងរបស់ចុងចោទត្រូវតែបកប្រែទៅជាភាសារបស់មេធាវីការពារនោះ"។[34] ក៏ប៉ុន្តែចំនុចនេះត្រូវមានអត្ថន័យខុសគ្នាបន្តិចបន្តួចដោយការព្រមទទួលស្គាល់ថា នៅពេលណាក៏ដោយ "មិនសូវមានករណីដែលតុលាការអន្តរជាតិផ្តល់ការអនុញ្ញាតលើសំណើបែបនេះណាស់។ តុលាការទាំងនោះ បានលើកទឹកចិត្តដល់ក្រុមមេធាវីការពារក្តីនានាឲ្យប្រើប្រាស់នូវសមត្ថភាពផ្នែកភាសាសាស្ត្រដែលមានស្រាប់នៅនឹងកន្លែង ដើម្បីដោះស្រាយឲ្យបានចំពោះការខ្វះខាតសមត្ថភាពខាងភាសាសាស្ត្ររបស់មេធាវីណាមួយនៅក្នុងភាសារបស់ចុងចោទ"[35] ដូច្នេះទទួលស្គាល់ថា មានការបកប្រែបែបនោះត្រូវបានបង្គាប់ឲ្យធ្វើរួចហើយ។ ប៉ុន្តែ អ្វីដែល ក.ស.ព ខកខានមិនបានលើកឡើង

---

33 សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៤៣ ។

34 សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៤៥ ។

35 សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៤៥ ។

តែមួយគត់នោះគឺថា ហេតុអ្វីក៏ការបកប្រែបែបនោះមិនត្រូវបានផ្តល់ជូននៅ អ.វ.ត.ក នេះទៅវិញ។

23. មេធាវីការពារបានស្នើឡើងយ៉ាងទូលំទូលាយថា ហេតុអ្វីបានជាវាមានសារៈសំខាន់ដែលការបកប្រែទៅជាភាសាអង់គ្លេសដើម្បីឲ្យលោក **អៀង សារី** ទទួលបាននូវកិច្ចការពារក្តីប្រកបដោយប្រសិទ្ធិភាពនោះ។[36] ក.ស.ព មិនបានជំទាស់តវ៉ាថា មានសិទ្ធិបែបនេះត្រូវបានអនុញ្ញាតផ្តល់ឲ្យលោក **អៀង សារី** នៅ អ.វ.ត.ក ហើយ ក.ស.ព ក៏មិនបានបង្ហាញឲ្យឃើញថាតើ ដីកាសម្រេចស្តីពីការបកប្រែមិនបានរំលោភដល់សិទ្ធិនេះដោយរបៀបណានោះដែរ។ ផ្ទុយទៅវិញ ក.ស.ព សំអាងថា មេធាវីអន្តរជាតិត្រូវបានគេ "រំពឹងទុកថា គាត់ត្រូវធ្វើការដោយសហការគ្នាជាមួយនឹងមេធាវីខ្មែរ និងប្រើប្រាស់នូវសមត្ថភាពខាងភាសាសាស្ត្រដែលបានផ្តល់អោយ និងដែលមានស្រាប់នៅក្នុងក្រុមមេធាវីការពារក្តី"។[37] មានការរិះគន់ដ៏សមហេតុផលពីរ ទៅលើការអះអាងបែបនេះ។

24. ទីមួយ មេធាវីការពារក្តីបានធ្វើកិច្ចសហការគ្នាខាងភាសាសាស្ត្រ ដោយការប្រើប្រាស់ធនធានមានកម្រិតរបស់ខ្លួនតាមមធ្យោបាយប្រសើរបំផុតដែលអាចធ្វើទៅបាន ដើម្បីការពារសិទ្ធិរបស់លោក **អៀង សារី** ។ បុគ្គលិកដែលនិយាយភាសាខ្មែរនៅក្នុងក្រុមមេធាវីការពារក្តីធ្វើការស្រាវជ្រាវផ្នែកច្បាប់ និងអង្គហេតុជាភាសាខ្មែរ ហើយក៏មានកាតព្វកិច្ចបំពេញការបកប្រែនៅក្នុងក្រុមរបស់ខ្លួននូវសារណាទាំងឡាយដាក់ជូនទៅអង្គបុរេជំនុំជម្រះ និង ក.ស.ច.ស។ ក៏ប៉ុន្តែ វាមានលក្ខណៈខុសគ្នាដែលជាបច្ច័យសំខាន់រវាងឯកសារដែលតាក់តែងឡើងដោយមេធាវីការពារ និងភស្តុតាងគរដូចភ្នំដែលអះអាងគាំទ្រដល់ការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលបានដាក់ជូនដោយ ក.ស.ព ។

25. ទីពីរ ពាក្យពេចន៍ដែល ក.ស.ព បានប្រើប្រាស់មានលក្ខណៈជាការបង្គាប់បញ្ជា។ មេធាវីការពារត្រូវបានលើកទឹកចិត្ត ឬរំពឹងអោយមានកិច្ចសហការនៅក្នុងក្រុមមេធាវីការពារ។ ពុំមានកាតព្វកិច្ចឲ្យធ្វើបែបនេះត្រូវបានអះអាង ត្រូវបានបង្ហាញបន្តិចបន្តួចដោយ ក.ស.ព ឡើយ។ ទោះបីជាក្រុមមេធាវីការពាររបស់ **អៀង សារី** បានសហការទាំងនៅក្នុងក្រុមខ្លួនឯង និងសហការជាមួយផ្នែកគាំពារការការពារក្តី ក្រុមអ្នកបកប្រែITPក៏ដោយ ក៏កិច្ចសហការនេះមិនអាចត្រូវបានយកមកប្រើប្រាស់ជាយុត្តិកម្មចំពោះការរំលោភសិទ្ធិរបស់លោក **អៀង សារី** នោះទេ។

---

[36] បណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែ កថាខណ្ឌ ២១-២៦ ។

[37] សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៤៦ ។

00223759



## ឃ. ការរំលោភបំពានសមភាពនៃមធ្យោបាយតទល់ក្តីគ្នាដោយប្រព័ន្ធបកប្រែភាសាដែលបង្គាប់ដោយ ក.ស.ច.ស

26. ក.ស.ព មានអំណះអំណាងថា ការផ្តល់អ្នកបកប្រែភាសាជាក់លាក់មួយទៅឲ្យក្រុមមេធាវីការពារ "មិនបានបង្កើតកាតព្វកិច្ចថ្មីណាមួយសម្រាប់មេធាវីការពារនោះទេ ប៉ុន្តែ វាជាការស្វែងរកការបំពេញបន្ថែមសមត្ថភាពខាងភាសាសាស្ត្រដែលមានស្រាប់របស់ពួកគេ ដើម្បីលើកស្ទួយសិទ្ធិរបស់ចុងចោទក្នុងការទទួលបានកិច្ចការពារក្តីប្រកបដោយប្រសិទ្ធិភាព"។[38] ទឡ្ហីករណ៍នេះជាការកាត់យល់ខុសចំពោះការរំលោភបំពានលើសមភាពនៃមធ្យោបាយតទល់ក្តីគ្នា នាពេលបច្ចុប្បន្ន និងដែលចេះតែបន្ត ដែលកើតឡើងដោយសារការដាក់ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលមិនទាន់បានបកប្រែឲ្យទៅជាភាសាទាំងបីរបស់តុលាការនេះនៅឡើយ។ ក្នុងខណៈដែល ដីកាសម្រេចស្តីពីការបកប្រែ ប្រហែលជាបន្ធូរបន្ថយបន្តិចបន្តួចចំពោះការរំលោភដ៏ធ្ងន់ធ្ងរនេះដោយការផ្តល់ការបកប្រែផ្ទាល់មាត់នូវឯកសារខ្លះ តែវាមិនបានជួសជុលទាំងស្រុងដល់ការរំលោភនេះបានទេ។ ចំនុចនេះអាចសម្រេចទៅបាន លុះត្រាតែមានការបកប្រែឯកសារទាំងអស់ដែលមេធាវីការពារបានស្នើសុំ។ ដោយព្យាយាមដើម្បីបង្ហាញថា ស្ថានភាពបច្ចុប្បន្នគឺមានយុត្តិធម៌ពេញលេញដល់មេធាវីការពារ និងថា អ្នកបកប្រែភាសាគឺជាធនធានបន្ថែមដែលត្រូវបានផ្តល់ជូននោះ ក.ស.ព ទាំងធ្វើអោយគេយល់ផ្សេងពីការពិតដោយចេតនា ឬ ក៏ទាំងកាត់យល់ខុសដោយអចេតនានូវតថភាពពិតនៃស្ថានភាពនេះ។

27. កំហុសស្រដៀងគ្នានេះដែរ គឺការវាយតម្លៃរបស់ ក.ស.ព មកលើការជំទាស់របស់មេធាវីការពារចំពោះប្រព័ន្ធបកប្រែភាសាដែលបានអនុវត្តដោយ ក.ស.ច.ស ។ ប្រព័ន្ធនេះនឹងតម្រូវឲ្យមេធាវីការពារ ធ្វើការដាក់ជូនសំណើសុំការបកប្រែចំដែលៗជាលក្ខណៈបុគ្គលទៅក្រុមអ្នកបកប្រែ ដែលទំនងជានឹងបកប្រែជូន ប្រសិនបើមានចំនួនគ្រប់គ្រាន់នៃភាគីដទៃទៀតនៅក្នុងនីតិវិធីនេះដែលត្រូវការឯកសារទាំងនេះដែរ។ ចំនុចនេះនឹងដាក់បន្ទុកផ្នែករដ្ឋបាលដែលមិនចាំបាច់ មកលើក្រុមមេធាវីការពារ។ វាក៏នឹងផ្តល់លទ្ធផលដែលមិនគួរឲ្យជឿងឆ្ងល់ អោយទៅជាការបែកខ្ញែកគ្នាដែលមិនជាការចាំបាច់រវាងក្រុមមេធាវីការពារក្តី ខណៈដែលក្រុមនីមួយៗនឹងត្រូវចង្អុលបង្ហាញថាហេតុអ្វី

---

[38] សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៤៩ ។

បានជាឯកសារដែលខ្លួនមានបំណងឲ្យគេបកប្រែ គួរត្រូវមានអាទិភាពជាងសំណើរបស់ក្រុមផ្សេងទៀតនោះ។

28. ចេតនារបស់ ក.ស.ព ក្នុងការណែនាំនូវការដាក់កម្រិតដោយសន្មតមកលើការជ្រើសរើសមេធាវីដោយសេរីរបស់លោក **អៀង សារី** ដោយស្នើឡើងថា គាត់ត្រូវ "ជ្រើសរើសមេធាវីអន្តរជាតិមួយរូបដែល ដែលរស់នៅទីក្រុងភ្នំពេញដើម្បីធ្វើជាមេធាវីតំណាងគាត់កាន់តែមានប្រសិទ្ធិភាពថែមទៀត"[39] មិនជាប់ពាក់ព័ន្ធទៅនឹងបញ្ហានាពេលបច្ចុប្បន្ននេះទេ។ លោក **អៀង សារី** បានអនុវត្តសិទ្ធិរបស់គាត់ដោយស្ម័គ្រចិត្តក្នុងការជ្រើសរើសមេធាវីអន្តជាតិ។ គុណវុឌ្ឍិរបស់មេធាវីដែលតម្រូវដោយអង្គភាពគាំពារការការពារក្តី មិនបាននិយាយពីកាតព្វកិច្ចត្រូវរស់នៅទីក្រុងភ្នំពេញ នៅក្នុងអម្លុងពេលនៃដំណាក់កាលស៊ើបសួរនោះទេ។[40] ផ្ទុយទៅវិញ តាមការពិត នៅក្នុងដំណាក់កាលនេះ "គេមិនបានរំពឹងថា សហមេធាវីនឹងបំពេញការងារពេញម៉ោងទៅលើរឿងក្តីនៅក្នុងដំណាក់កាលស៊ើបសួរនេះទេ គឺអនុញ្ញាតឲ្យពួកគាត់រក្សាការងារវិជ្ជាជីវៈធម្មតារបស់ខ្លួនបាន"[41] ដូច្នេះហើយ ការរើទីតាំងមកនៅទីក្រុងភ្នំពេញក៏មិនត្រូវបានគេប្រមើលមើលទុកជាមុននោះដែរ។ លើសពីនេះទៅទៀត អ.វ.ត.ក ផ្តល់លទ្ធភាពឲ្យទទួលបានសំណុំរឿងពីចម្ងាយ ដូចនេះ មេធាវីអន្តរជាតិអាចមាន លទ្ធភាពទទួលបានសំណុំរឿងដូចគ្នានឹងមេធាវីដែលមានទីតាំងនៅទីក្រុងភ្នំពេញ។ ហេតុដូច្នេះ ការអះអាងរបស់ ក.ស.ព ថា កាតព្វកិច្ចតុលាការក្នុងការផ្តល់ទីកន្លែង និងសម្ភារៈ(ផាសុបករណ៏) សម្រាប់ការរៀបចំកិច្ចការពារក្តី គឺមិន"សំដៅទៅដល់ការផ្តល់ផាសុបករណ៏ផ្សេងៗនៅទីកន្លែងណាមួយនៅក្នុងពិភពលោកនោះ" មិនត្រឹមត្រូវទេ[42]។

---

[39] សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៥១ ។

[40] លក្ខណៈវិនិច្ឆ័យដែលបានតម្រូវចំពោះសហមេធាវីអន្តរជាតិ មានដូចតទៅនេះ: i) បច្ចុប្បន្នជាសមាជិកគណៈមេធាវី ដែលមានការទទួលស្គាល់នៅក្នុងរដ្ឋដែលជាសមាជិកអង្គការសហប្រជាជាតិ និងជាមេធាវីដែលមានកេរ្តិ៍ឈ្មោះល្អ ii) មានសញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រសមមូល ឬសញ្ញាប័ត្រប្រកបវិជ្ជាជីវៈ iii) មានបទពិសោធន៏ការងារយ៉ាងតិច ១០ ឆ្នាំពាក់ព័ន្ធទៅនឹងដំណើរការនីតិវិធីព្រហ្មទណ្ឌ អាចជាមេធាវី ជាចៅក្រម ឬជារដ្ឋអាជ្ញា ឬនៅក្នុងសម្តភាពការងារផ្សេងទៀត iv) មានសមត្ថភាពនៅក្នុងច្បាប់ និងនីតិវិធីព្រហ្មទណ្ឌនៅកម្រិតជាតិ ឬអន្តរជាតិ v) ចេះនិយាយភាសាខ្មែរ ភាសាបារាំង ឬភាសាអង់គ្លេសបានស្ទាត់ជំនាញ និង vi) ទទួលបានការអនុញ្ញាតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឲ្យការពារក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ សូមមើល http://www.eccc.gov.kh/english/dss_the_list_aspx

[41] មគ្គុទ្ទេសន៏ណែនាំចំពោះគ្រោងការជំនួយការច្បាប់នៅ អ.វ.ត.ក ចុះថ្ងៃទី២១ មករា ២០០៨។ F.2.

[42] សារណាឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៥២ ។

29. គ្មានអ្វីដែលបានដាក់ជូនដោយ ក.ស.ព ដើម្បីតតាំងនឹងការជំទាស់របស់មេធាវីការពារចំពោះការបកប្រែភស្តុតាងដោយផ្ទាល់មាត់បាន ក្រៅតែពីការបកប្រែសំណេរជាផ្លូវការដែលបានផ្តល់ដោយផ្នែកគ្រប់គ្រងតុលាការនោះទេ។ កង្វះខាតតាមរយៈការបកប្រែផ្ទាល់មាត់ត្រូវបានពន្យល់យ៉ាងច្បាស់នៅក្នុងសេចក្តីសម្រេចដោយផ្ទាល់មាត់នាពេលថ្មីៗរបស់ ICC នៅក្នុងរឿងក្តីរបស់ *Lubanga* ។ អង្គបុរេជំនុំជម្រះបានប្រឈមមុខនឹងសំណួរដ៏ស្មុគ្រស្មាញថាតើខ្លួនអាចពិនិត្យមើលឯកសារសម្ងាត់ ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់អយ្យការឡើងវិញដោយរបៀបណា ដើម្បីបញ្ជាក់ថាតើឯកសារទាំងនោះជាភស្តុតាងដោះបន្ទុក ឬយ៉ាងណានោះ។ អយ្យការដែលបានទទួលឯកសារសម្ងាត់ បានលើកឡើងថា ចៅក្រមទាំងអស់អាចពិនិត្យមើលឯកសារនៅក្នុងទីតាំងជាក់លាក់មួយ និងគ្រាន់តែកត់ត្រាទៅតាមការចងចាំរបស់ពួកគាត់ នៅពេលពួកគាត់ចាកចេញទៅវិញ។ នៅក្នុងការវាយតម្លៃទៅលើសំណើបែបនេះ មានការលើកឡើងថា អង្គបុរេជំនុំជម្រះ៖

> "ទំនងជាមិនសម្រេចយកប្រព័ន្ធមួយដែលពឹងផ្អែកទៅលើសមត្ថភាពរបស់ខ្លួនក្នុងការចងចាំបរិមាណព័ត៌មានដ៏សន្ធឹកសន្ធាប់ ដែលខ្លួនមិនអាចរក្សាទុក និងសិក្សាបាន ហើយលើសពីនេះទៅទៀត គឺខ្លួនមិនអាចធ្វើការប្រៀបធៀបជាមួយភស្តុតាងដទៃទៀតនៅក្នុងរឿងក្តីបាននោះ"[43]។

30. គួរឱ្យកត់សម្គាល់ផងដែរថា ចំនួនភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលកំពុងតែពិនិត្យឡើងវិញ គឺជាភស្តុតាងដែលបានសរសេរជាភាសាបារាំង មិនមែនជាភាសានិយាយរបស់ចៅក្រម។ នៅពេលព័ត៌មាននេះត្រូវបានបញ្ជូនទៅការិយាល័យអយ្យការភ្លាមនោះ ក៏មានការផ្តល់ការបកប្រែឯកសារទាំងអស់នេះទៅជាភាសាអង់គ្លេសដើម្បីអាចឱ្យពិនិត្យឯកសារទាំងនេះបាន។[44] ពុំមានកាតព្វកិច្ចនៃកិច្ចសហការគ្នារវាងចៅក្រមដែលចេះនិយាយភាសាបារាំង និងចៅក្រមដែលមិនចេះនិយាយភាសាបារាំងនោះទេ។ ដូច្នេះ មេធាវីការពារក្តីសូមស្នើថា ការផ្តល់ការបកប្រែផ្ទាល់មាត់នូវឯកសារដែលគាំទ្រដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ការតម្រូវឱ្យមេធាវីការពារចងចាំនូវបរិមាណព័ត៌មានដ៏ច្រើនសន្ធឹកសន្ធាប់ ដែលការចងចាំបែបនេះមិនអាចធ្វើការប្រៀបធៀបទៅនឹងភស្តុតាង

---

[43] រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង* Lubanga ICC-01/04/01/06 ប្រតិចារិកសវនាការចុះថ្ងៃទី ២៤ មិថុនា ២០០៨ ទំព័រ ៣០ ដល់ ៣៣ ។

[44] រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង* Lubanga ICC-01/04/01/06 ប្រតិចារិកសវនាការចុះថ្ងៃទី ២៤ មិថុនា ២០០៨ ទំព័រ ៣០ ។

ផ្សេងទៀតនៅក្នុងសំណុំរឿងបាននោះ ក៏មិនមានប្រសិទ្ធិភាពដូចគ្នានេះដែរ។ ហេតុដូច្នេះហើយ ត្រូវតែផ្តល់ការបកប្រែសំណេរឲ្យបានពេញលេញ។

31. ទីបំផុត ការណ៍ដែល ក.ស.ព អះអាងថា សិទ្ធិទទួលបានសមភាពនៃមធ្យោបាយតទល់ក្តីគ្នា មិនត្រូវបានរំលោភបំពាន ដោយសារថា មេធាវីការពារបាន "ជ្រើសរើសមិនប្រើប្រាស់នូវផាសុបករណ៍ (សម្ភារៈ) [sic] ដែលផ្តល់ដោយសេវាកម្មរបស់ផ្នែកគ្រប់គ្រងតុលាការសំរាប់ការបកប្រែឯកសារទាំងឡាយ"[45] គឺមិនមានអ្វីជាសំអាងដែរ។ មេធាវីមិនយល់ស្របទាល់តែសោះជាមួយនឹងប្រព័ន្ធដែលដាក់អោយអនុវត្តដោយ ក.ស.ច.ស ដូចដែលបានបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែ ។ ការជ្រើសរើសមិនទទួលផាសុបករណ៍(សម្ភារៈ)ដែលមានលក្ខណៈមិនគ្រប់គ្រាន់បែបនេះ មិនគួរយកមកធ្វើជាហេតុផលបដិសេធទឡ្ហីករណ៍របស់មេធាវីការពារនោះទេ។ នេះគ្រាន់តែបង្ហាញពីភាពស៊ីសង្វាក់គ្នានៃជំហររបស់មេធាវីការពារក្នុងពាក្យសម្តី និងសកម្មភាពតែប៉ុណ្ណោះ។

## IV. សេចក្តីសន្និដ្ឋាន និង ការស្នើសុំដោះស្រាយ

32. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលដាក់ជូនដោយ ក.ស.ព ប្រឆាំងមកលើលោក **អៀង សារី** កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ បានផ្លាស់ប្តូរដោយមិនត្រឹមត្រូវនូវបន្ទុកនៃការបកប្រែឯកសារដែលអះអាងគាំទ្រដល់ការចោទប្រកាន់ដែលមាននៅក្នុងដីកានោះ ពី ក.ស.ព ទៅ ក.ស.ច.ស ។ ដីកាសម្រេចស្តីពីការបកប្រែ បែរទៅផ្លាស់ប្តូរបន្ទុកនេះទៅឲ្យក្រុមការពារក្តីនីមួយៗ ដែលការទំនុកបំរុងក្នុងការបកប្រែមានបរិមាណយ៉ាងតិចតួចបំផុត ហើយការបកប្រែនេះត្រូវការយ៉ាងបន្ទាន់បំផុត។ ការទម្លាក់ការទទួលខុសត្រូវរបស់តុលាការ (ការផ្ទេរការទទួលខុសត្រូវ និង/ឬ ការស្តីបន្ទោស) គឺជារឿងមួយមិនល្អ។ វាជាដីកាគួរឲ្យសោកស្តាយមួយនៃទំនាក់ទំនងរវាង ក.ស.ព និង ក.ស.ច.ស។ អង្គបុរេជំនុំជម្រះត្រូវតែដោះស្រាយបញ្ហាទាក់ទងទៅនឹងការបកប្រែ ដែលបានលើកឡើងនៅក្នុង បណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែឲ្យបានគ្រប់គ្រាន់ និងឆាប់រហ័សបំផុត។ ការប្រព្រឹត្តផ្សេងពីនេះ ធ្វើអោយមានហានិភ័យកើតមានជាមន្ទិលសង្ស័យយ៉ាងខ្លាំងមកលើការប្តេជ្ញាចិត្ត និង

[45] ចម្លើយតបរបស់ ក.ស.ព កថាខ័ណ្ឌ ៥២ ។

ភាពស្មោះត្រង់របស់ អ.វ.ត.ក ក្នុងការសម្រេចគោលបំណងរបស់ខ្លួនដែលបានលើកឡើងគឺ "ការស្វែងរកយុត្តិធម៌"[46]។

**អាស្រ័យហេតុនេះ** ចំពោះហេតុផលទាំងអស់ដែលបានលើកឡើងនៅក្នុងសំណើឆ្លើយតបនេះ មេធាវីការពារ សូមសំណូមពរដោយគោរពមកអង្គបុរេជំនុំជម្រះដើម្បី៖

ក. ទុកជាមោឃៈភាព "ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ" របស់ ក.ស.ច.ស ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ។

ខ. បង្គាប់ឲ្យផ្នែកគ្រប់គ្រងតុលាការធ្វើការបកប្រែជាបន្ទាន់នូវឯកសារទាំងអស់ ដែលបានដាក់ជូនដោយ ក.ស.ព ដែលគាំទ្រដល់ការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

គ. បង្គាប់ឲ្យផ្នែកគ្រប់គ្រងតុលាការធ្វើការបកប្រែឯកសារទាំងអស់នៅក្នុងសំណុំរឿង ដោយមិនគិតថា ឯកសារទាំងអស់នោះបង្កើតបានជាធាតុផ្សំនៃភស្តុតាងឬមួយក៏អត់។

សូមអង្គបុរេជំនុំជម្រះទទួលយកសំណើឆ្លើយតបនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៨

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

46 បុព្វកថានៅក្នុងវិធានផ្ទៃក្នុង។